**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ**
**THE STUDENT MOVEMENT FOR DEMOCRACY**

លេខ៖ ០០១៦/២០ ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០

# សេចក្តីបំភ្លឺ

## ជូនគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន នៃរដ្ឋាភិបាលកម្ពុជា

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមបដិសេធទាំងស្រុង ចំពោះសេចក្តីថ្លែងការណ៍នៃ **គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា** លេខពិសេស៥ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ ដែលធ្វើការចោទប្រកាន់មិនចំពោះ, គ្មានមូលដ្ឋាន និងមានចរិតគំរាមកំហែង មកលើក្រុមបញ្ញវន្ត សកម្មជនព្រំដែន និងក្រុមអ្នកជំនាញព្រំដែន ដែលជាអ្នកតស៊ូមតិដើម្បីការពារអធិបតេយ្យ និងបូរណភាពទឹកដី ស្របតាមរដ្ឋធម្មនុញ្ញកម្ពុជា និងតាមគោលការណ៍ច្បាប់ជាតិ-អន្តរជាតិជាមូលដ្ឋាន។

ដើម្បីជៀសវាងការភាន់ច្រឡំពីមតិសាធារណៈ លើការខ្វែងគំនិតគ្នាក្នុងការការពារអធិបតេយ្យ បូរណភាពទឹកដី និងដើម្បីលើកកំពស់ស្មារតីឯកភាពជាតិខ្មែរ **ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមធ្វើការបំភ្លឺជូន **គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា** ដូចតទៅ៖

**១- ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** មិនមែនជា«ក្រុមឧទ្ទាម និងគូកន» ដូចការចោទប្រកាន់នៅក្នុងសេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា នោះទេ។

យើងខ្ញុំជា**ក្រុមបញ្ញវន្តខ្មែរ** ដែលតែងតែយកចិត្តទុកដាក់អំពីបញ្ហាព្រំដែនជាតិខ្មែរ និងធ្វើពលិកម្មដើម្បីរួមចំណែកការពារទឹកដីខ្មែរ ក្នុងកាតព្វកិច្ចជាពលរដ្ឋល្អ របស់ជាតិកម្ពុជា។ យើងខ្ញុំធ្វើការងារព្រំដែន តាមគោលការណ៍ច្បាប់យ៉ាងខ្ជាប់ខ្ជួន ដោយជម្រុញឲ្យភាគីពាក់ព័ន្ធ ទាំងអាជ្ញាធររដ្ឋាភិបាលកម្ពុជា និងទាំងប្រទេសជិតខាង **ឲ្យគោរពច្បាប់អន្តរជាតិ ក្នុងការដោះស្រាយបញ្ហាព្រំដែន** ដូចជាអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ (UNCLOS1982), កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១, និងផែនទីរបស់កម្ពុជា ដែលតម្កល់នៅអង្គការសហប្រជាជាតិ ជាដើម។ ទាំងនេះគឺជាកិច្ចការស្របតាមគោលការណ៍ច្បាប់ជាតិ-អន្តរជាតិ **មិនមែនជាសកម្មភាពបែបឧទ្ទាម** ទេ។

**២-** ការបម្លែងមាត្រដ្ឋានផែនទី ខ្នាត ១/២៥.០០០ **ធ្វើឡើងស្ងាត់ៗ** ជាមួយវៀតណាម ដោយគ្រាន់តែប្រើពាក្យថា ***«ដូចមាននៅលើផែនទីបោន (Bonne) ខ្នាត ១/១០០.០០០»*** **គឺនាំមកនូវភាពមន្ទិលសង្ស័យ អំពីសុក្រឹតភាពនៃការបម្លែងមាត្រដ្ឋានផែនទី និងសមភាព**របស់កម្ពុជានៅក្រោមឥទ្ធិពលវៀតណាម។ **បើសិនរដ្ឋាភិបាលកម្ពុជា ពិតជាធ្វើកិច្ចការបម្លែងផែនទីនេះ បានត្រឹមត្រូវមែននោះ រដ្ឋាភិបាលពុំមានហេតុផលអ្វី ត្រូវលាក់បាំងឡើយ**។ ដោយសារការបម្លែងខ្នាតផែនទី ធ្វើឡើងដោយស្ងាត់ៗបែបនេះ នាំឲ្យយើងខ្ញុំ និងសារណៈមតិ មានចម្ងល់ថា៖

ផែនទី ខ្នាត ១/២៥.០០០ ថ្មីទាំងនោះ បម្លែងពីមាត្រដ្ឋានផែនទីបោន ១/១០០.០០០ តើធ្វើបានប៉ុន្មានផ្ទាំង? តើផែនទីបោន ខ្នាត ១/១០០.០០០ គំរូដើមទាំងនោះ ជាផែនទីពិត បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិនមែនឬទេ? ហើយជាផែនទីដែលមានតម្កល់ទុកនៅអង្គការសហប្រជាជាតិឬយ៉ាងណា?

ជាក់ស្តែង ការបម្លែងផែនទី បានធ្វើឡើងដោយស្ងាត់ៗ ហើយ**«គោលការណ៍ដោះដូរដី មួយស្មើមួយ»** ក៏ធ្វើឡើងដោយស្ងាត់ៗដែរ។ រាល់ពេលដែលរដ្ឋាភិបាលកម្ពុជា និយាយអំពីការដោះដូរដីភូមិជាមួយវៀតណាម ប្រជាពលរដ្ឋខ្មែរនៅតាម ព្រំដែនស្រែកយំជាហូរហែរពីការបាត់ដីស្រែចំការរបស់ពួកគាត់ ដោយសារតែការទន្ទ្រានឈ្លានពានយក ពីសំណាក់ប្រទេស វៀតណាម។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ រដ្ឋាភិបាលកម្ពុជា ក៏មិនបានធ្វើរបាយការណ៍ត្រឹមត្រូវ ប្រាប់ទៅប្រជាពលរដ្ឋខ្មែរជាសាធារណៈ អំពីការដោះដូរភូមិ និងដីស្រែចំការ ដែលទទួលបាន និងបាត់បង់ពី**«គោលការណ៍ដោះដូរ មួយស្មើមួយ»** ឡើយ។ ដូច្នេះ **រដ្ឋាភិបាលកម្ពុជា ត្រូវធ្វើរបាយការណ៍ឲ្យបានលម្អិត ពីចំនួនភូមិខ្មែរ និងភូមិវៀតណាម ដែលប្រទេសទាំងពីរ បានដោះដូរគ្នាកន្លងមក។**

ដើម្បីជម្រុះមន្ទិលសង្ស័យនានា រដ្ឋាភិបាលកម្ពុជា ត្រូវបង្ហាញនូវផែនទី ខ្នាត ១/២៥.០០០ ដែលបម្លែងថ្មីទាំងអស់ និង ផែនទីបោន ខ្នាត ១/១០០.០០០ ដែលជាគំរូដើម ជាសាធារណៈ។ ជាមួយគ្នានេះ ត្រូវអញ្ជើញអ្នកជំនាញផែនទី របស់អង្គការសហប្រជាជាតិ និងភាគីពាក់ព័ន្ធ រួមទាំងប្រទេសបារាំង ដែលជាម្ចាស់គំនូសផែនទីដើម របស់ប្រទេសកម្ពុជា ដើម្បីបញ្ជាក់អំពីសុក្រឹតភាពនៃការបម្លែងមាត្រដ្ឋានផែនទី។

**៣- គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា** បានប្រើពាក្យ **«ដេញថ្លៃជាអន្តរជាតិ»** ក្នុងការបោះពុម្ពផែនទី។ ការអះអាងរបស់គណៈកម្មាធិការនេះ មានកំហុស ២យ៉ាង ក្នុងបំណងបំភាន់ពលរដ្ឋខ្មែរ៖ **ទី១.** រដ្ឋាភិបាល គ្រាន់តែនិយាយអំពីការ**«ដេញថ្លៃជាអន្តរជាតិ»** ប៉ុន្តែពលរដ្ឋខ្មែរ មិនបានដឹង ហើយមិនឃើញមានបណ្តាញសារពត៌មានក្នុងស្រុក និងអន្តរជាតិណាមួយ ចុះផ្សាយអំពីការដេញថ្លៃនេះទេ។ **ទី២.** ទោះបីក្រុមហ៊ុនដែលដេញថ្លៃទទួលបានអាជ្ញាប័ណ្ណបោះពុម្ពផែនទី គឺមានសិទ្ធិត្រឹមតែបោះពុម្ពតាមការណែនាំរបស់ភាគីវៀតណាម និងកម្ពុជាប៉ុណ្ណោះ ដោយពុំមានសិទ្ធិវែកញែកផ្ទៀងផ្ទាត់ ថាតើផែនទីបោះពុម្ពថ្មីនោះ ត្រឹមត្រូវតាមគំរូដើមនៃផែនទី ខ្នាតបោន ឬខ្នាត យូធីអឹម (UTM) ឡើយ។

៤- រដ្ឋាភិបាលកម្ពុជា បានអះអាងថា ***«ផែនទីឋានលេខាព្រំដែន ខ្នាត ១/២៥.០០០ ជាផែនទីបង្ហាញពីលទ្ធផលប្រមាណជា ៨៤% ដែលកម្ពុជា និងវៀតណាម សម្រេចបានលើការងារព្រំដែន»***។ ការអះអាងនេះ ជាក់ស្តែងណាស់ថា រដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន បន្តគប់គិតជាមួយវៀតណាម **គូសផែនទីថ្មី ខ្នាត ១/២៥.០០០ ដើម្បីតម្រូវទៅតាមការបោះបង្គោលព្រំដែន បានចំនួន ៨៤% រួចហើយ។ ដោយសារការគប់គិតនេះហើយ បានធ្វើឲ្យប្រជាពលរដ្ឋខ្មែរនៅតាមព្រំដែនគ្រប់តំបន់ រងការឈឺចាប់ពីការបាត់បង់ដីស្រែចំការរបស់ពួកគាត់ ទៅក្រោមការគ្រប់គ្រងរបស់វៀតណាម។**

ទង្វើរបស់រដ្ឋាភិបាលកម្ពុជាខាងលើនេះ **គឺជាការធ្វើសម្បទានម្តងហើយហើយម្តងទៀត ឲ្យទៅវៀតណាម ដែលមិនអាចប្រកែកបានឡើយ** ជាពិសេសការចុះហត្ថលេខាទទួលស្គាល់ផែនទីថ្មី ខ្នាត ១/២៥.០០០ កាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ ឲ្យត្រូវនឹងលទ្ធផលនៃការបោះបង្គោលព្រំដែនរួចហើយ។

**ជ.គណៈកម្មាធិការប្រតិបត្តិ**

**អនុប្រធាន**

**អ៊ុំ សេង**